CITY OF LONGBEACH PRESS RELEASE

**សេចក្តីប្រកាសព័ត៌មាន**

ថ្ងៃទី ៤ ខែមិថុនាឆ្នាំ ២០២០
ទំនាក់ទំនង៖ មជ្ឈមណ្ឌលព័ត៌មានរួមនៃទីក្រុងឡុងប៊ិច ៥៦២.៥៧០.NEWS (៦៣៩៧)
jic@longbeach.gov

សម្រាប់សេចក្តីប្រកាសជាបន្ទាន់

# ទីក្រុងឡុងប៊ិចប្រកាសថាមិនមានបម្រាមគោចរសម្រាប់ថ្ងៃនេះ ថ្ងៃទី ៤ ខែមិថុនាទេ

ទីក្រុងឡុងប៊ិច, រដ្ឋកាលីហ្វ័រញ៉ា - ទីក្រុងឡុងប៊ិចបានប្រកាសថាមិនមានបម្រាមគោចរសម្រាប់ថ្ងៃនេះថ្ងៃទី ៤ ខែមិថុនាទេដែលស្របនឹងខោនធី Los Angeles ដែលមិនបានដាក់បម្រាមគោចរទូទាំងខោនធីថ្ងៃនេះទេ។ ការសម្រេចចិត្តថាតើត្រូវដាក់តបំរាមគោចរឬមិននឹងបន្តវាយតម្លៃជារៀងរាល់ថ្ងៃ។

លោក Tom Modica ប្រធានគ្រប់គ្រងក្រុងបានមានប្រសាសន៍ថា "ការសម្រេចមិនអនុវត្តបំរាមគោចរនៅថ្ងៃនេះគឺធ្វើដោយផ្អែកទៅលើសកម្មភាពបាតុកម្មតវ៉ាដោយសន្តិវិធីថ្មីៗនេះរបស់ក្រុមអ្នកតវ៉ាក៏ដូចជាការយល់ដឹងអំពីស្ថានភាពបច្ចុប្បន្ននៅឡុងប៊ិចនិងទូទាំងតំបន់។ យើងប្តេជ្ញា ១០០ ភាគរយនឹងគាំទ្រសិទ្ធិរបស់រដ្ឋធម្មនុញ្ញរបស់មនុស្សគ្រប់គ្នាទន្ទឹមនឹងការការពារអ្នកតវ៉ា អាជីវកម្ម ប្រជាជន គ្រួសារនិងសហគមន៍របស់យើងទាំងមូល។"

បម្រាមគោចរត្រូវបានអនុវត្តនៅទូទាំងទីក្រុងឡុងប៊ិចនិងខោនធី Los Angeles ដោយចាប់ផ្តើមពីល្ងាចថ្ងៃអាទិត្យទី ៣១ ខែឧសភានិងបញ្ចប់នៅព្រឹកថ្ងៃព្រហស្បតិ៍ទី ៤ ខែមិថុនា។

ទីក្រុងដឹងអំពីការបាតុកម្មតវ៉ាដោយសន្តិវិធីមួយដែលបានគ្រោងធ្វើនៅថ្ងៃនេះហើយមន្ទីរប៉ូលីសនៃទីក្រុងឡុងប៊ិចនឹងរៀបចំដើម្បីធានានូវសិទ្ធិអនុវត្តវិសោធនកម្មទីមួយរបស់សហរដ្ឋអាមេរិកនិងសុវត្ថិភាពរបស់អ្នកចូលរួមទាំងអស់។ ទីក្រុងបានដកការបិទផ្លូវបណ្តោះអាសន្នទាំងអស់ដែលទាក់ទងនឹងព្រឹត្តិការណ៍ថ្មីៗនេះ។

នៅថ្ងៃទី ៣១ ខែឧសភាឆ្នាំ ២០២០ លោកប្រធានក្រុង Tom Modica ក្នុងនាមជានាយកមន្ទីរការពារស៊ីវិលនៃទីក្រុងឡុងប៊ិចបានប្រកាសភាពអាសន្នក្នុងតំបន់នៅឡុងប៊ិចនិងបានបញ្ជាឱ្យមានបម្រាមគោចរតាមអំណាចដែលមានចែងក្នុងក្រមក្រុង។

នៅថ្ងៃទី ៣០ ខែឧសភាឆ្នាំ ២០២០ ដោយសារសកម្មភាពអស្ថិរភាពស៊ីវិលនិងធនធានក្នុងតំបន់មានកំរិតអភិបាលរដ្ឋ Gavin Newsom បានប្រកាសភាពអាសន្នក្នុងតំបន់សម្រាប់ខោនធី Los Angeles ហើយបានដឹកនាំប្រជាជនទាំងអស់ឱ្យធ្វើតាមដំបូន្មានរបស់មន្ត្រីសង្គ្រោះបន្ទាន់ក្នុងតំបន់។ ច្បាប់ក្រមនៃទីក្រុងឡុងប៊ិចលេខ 2.69 ផ្តល់សិទ្ធិអំណាចដល់នាយកមន្ទីរការពារស៊ីវិល (ប្រធានគ្រប់គ្រងក្រុង) ឱ្យប្រកាសពីភាពអាសន្នក្នុងតំបន់នៅពេលដែលទីក្រុងត្រូវរងផលប៉ះពាល់ឬទំនងនឹងរងផលប៉ះពាល់ដោយគ្រោះមហន្តរាយឬភាពអាសន្នធំដោយមានការផ្តល់សច្ចាប័នពីក្រុមប្រឹក្សាក្រុងក្នុងរយៈពេល ៧ ថ្ងៃឬក្នុងករណីដែលក្រុមប្រឹក្សាមិនស្ថិតក្នុងវគ្គប្រជុំ។

សម្រាប់ព័ត៌មានថ្មីៗអំពីជំងឺ COVID-19 រួមទាំងព័ត៌មានលម្អិតអំពីអ្វីដែលទីក្រុងឡុងប៊ិចកំពុងអនុវត្តដើម្បីការពារសុវត្ថិភាពដល់ប្រជាជនសូមមេត្តាចូលទៅកាន់គេហទំព័រ longbeach.gov/COVID19 ហើយតាមដាន @LongBeachCity នៅលើបណ្តាញសង្គមហ្វេសប៊ុក ធ្វីតធ័រ និង Instagram។

###